# ទំនុកដំកើង ១២១ សន្តិភាពមកពីព្រះ

អ្នកនិពន្ធ រ៉ុហ្វ លេភិឡារ

**ខ.១** ទំនុកដំកើងនេះចាប់ផ្តើមដោយសំនួរមួយអំពីទីណាដែលគាត់អាចរកបានសន្តិភាព។ ស្ថានភាពខុសគ្នាជាច្រើនអាចនាំឲ្យអ្នកនិពន្ធសួរសំនួរនេះ។ អត្ថន័យនៃពាក្យ *ភ្នំ* មិនច្បាស់លាស់ទេ តើវាមានន័យថាអ្នកនិពន្ធចង់យកភ្នំជាទីពឹងជ្រក ដូចជាភាពបន្ទាន់ដែលបានមកដល់ស្តេចដាវីឌនៅក្នុងទំនុកដំកើង ១១:១ «ចូររត់ទៅឯភ្នំរបស់ឯងដូចជាសត្វហើរចុះ»ឬ? ឬភ្នំនោះគឺជាកន្លែងមួយដែលមានឧបសគ្គ ឧទាហរណ៍ពីព្រោះពួកចោរប្លន់នៅទីនោះ? នៅក្នុងបរិបទអ្នកធម្មយាត្រានេះ (សូមមើល ការនែនាំសំរាប់ទំនុកដំកើង ១២០-១៣៤) ខនេះប្រហែលនិទានអំពីការមើលទៅឯភ្នំដោយសេចក្តីខ្វល់ខ្វាយពីព្រោះនៅទីនោះប្រហែលជាមានពួកចោរលួចប្លន់កំពុងតែលាក់ខ្លួន ឬមើលទៅឯភ្នំស៊ីយ៉ូនពីចំងាយហើយគិតថា «តើខ្ញុំអាចគេចចេញពីគ្រោះថ្នាក់ផ្សេងៗដែលខ្ញុំជួបប្រទះតាមផ្លូវ ហើយមកដល់ភ្នំស៊ីយ៉ូនយ៉ាងដូចម្តេច (១២៥:២)? ការការពារគឺជាបញ្ហាមួយសំរាប់អ្នកធម្មយាត្រាម្នាក់ដែលកំពុងធ្វើដំណើរតាមទឹកដីដែលស្ងាត់ជ្រងំ។

**ខ. ២** *ព្រះអម្ចាស់គឺជាព្រះដែលបង្កើតផ្ទៃមេឃនិងផែនដី៖* សេចក្តីពិតដែលថាព្រះយ៉ាវេបានបង្កើតគ្រប់ទាំងអស់មានន័យថា ទ្រង់គ្រប់គ្រងទាំងអស់ ហើយនេះគឺជាការកំសាន្តចិត្តដ៏អស្ចារ្យមួយសំរាប់អស់អ្នកដែលទុកចិត្តទ្រង់។ ដូច្នេះ នៅក្នុងខ.៣-៨ កិរិយាស័ព្ទ រក្សា» ត្រូវបានប្រើប្រាំមួយដង។ អ្នកនិពន្ធមិនដឹងថាគ្រោះថ្នាក់មកពីណាទេ ប៉ុន្តែគាត់ដឹងថាសន្តិភាពរបស់គាត់មកពីព្រះជាម្ចាស់។

**ខ. ៣-៤** នៅក្នុងខ.៣ ពាក្យភាសាហេព្រើរដែលបកប្រែ *«មិន»* គឺជាពាក្យត្រូវបានប្រើជាធម្មតាសំរាប់សំណូមពរនិងការទាមទារ។ ដូច្នេះ ខនេះប្រហែលមិនមែនជាសេចក្តីថ្លែងដែលខ៤នឹងនិយាយឡើងវិញនោះទេ ប៉ុន្តែខនេះប្រហែលជាសេចក្តីប្រាថ្នាឬសេចក្តីអធិស្ឋានមួយ ឧទាហរណ៍ «សូមឲ្យទ្រង់មិនឲ្យជើងអ្នករតលភ្លាត់ឡើយ សូមឲ្យព្រះអង្គដែលរក្សាអ្នក ទ្រង់នឹងមិនផ្ទុំរលីវឡើយ!» គឺជាសេចក្តីអធិស្ឋានមួយដែលខ៤-៨បានឆ្លើយតប។

ព្រះយ៉ាវេដែលប្រោសលោះកូនរបស់ទ្រង់គឺអ៊ីស្រាអែល (និក្ខមនំ ៤:២២) នឹងមិនបាត់បង់កូននៅតាមផ្លូវមកផ្ទះនោះទេ!

កំណត់សំគាល់៖ រតលជើង (ខ.៣) គឺជាឃ្លារួមមួយនៅក្នុងទំនុកដំកើង (១៧:៥, ៣៧:៣១, ៣៨:១៦, ៦៦:៩, ៧៣:២, ៩៤:១៨។

កំណត់សំគាល់៖ ផ្ទំរលីវ (ខ. ៣)។ នៅក្នុងអក្សរសាស្ត្ររបស់ពួកមេសូប៉ូតាមា ព្រះដែលផ្ទំរលីវគឺជាព្រះដែលមិនឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់អ្នកដែលកំពុងស្រែកសុំជំនួយ។ នៅក្នុងសេចក្តីអធិស្ឋានមួយរបស់ពួកបាប៊ីឡូន អ្នកថ្វាយបង្គំឆ្ងល់ពីពេលយូរប៉ុណ្ណាដែលព្រះនឹងផ្ទុំលក់។

**ខ. ៥-៨** ខគម្ពីរទាំងនេះបង្រៀនថា ព្រះយ៉ាវេ (នៅខាងស្តាំអ្នក) ទតរំពៃមកកាន់ពួកយើងនៅក្នុងគ្រប់ស្ថានភាពនិងគ្រប់ពេលវេលា។ មិនមានពេលណាដែលព្រះមិនកំពុងទតរំពៃមកយើងនោះទេ។ យើងអាចប្រៀបធៀបពាក់កណ្តាលទាំងពីររបស់ខ.៧ជាមួយនឹងលូកា ២១:១៨-១៩...ដែលបង្រៀនអំពីការថែរក្សារបស់ព្រះ («សូម្បីតែសក់មួយសរសៃលើក្បាលអ្នករាល់គ្នា ក៏មិនត្រូវវិនាសបាត់ផង») ត្រូវបានព្រះសន្យាក្នុងពេលតែមួយជាមួយនឹងសេចក្តីសន្យាអំពីការបៀតបៀននិងឧបសគ្គហើយសូម្បីតែទុក្ករកម្មទៀតផង (លូកា ២១:១៦-១៧...)។

**ការអនុវត្ត**

ទំនុកដំកើងនេះបង្ហាញថា យើងអាចទុកចិត្តព្រះជាម្ចាស់ទាំងស្រុងក្នុងការថែរក្សាយើង។ ទោះបើពិភពលោកផ្តល់ឲ្យយើងនូវឧបសគ្គហើយទោះបើជារឿយៗយើងមិនដឹងថាឧបសគ្គនឹងមកពីណា ក៏សន្តិភាពរបស់យើងគឺមាននៅក្នុងព្រះ ហើយការនេះផ្តល់ឲ្យយើងនូវសន្តិភាព។ ដូច្នេះ ទំនុកដំកើងនេះមិនកំពុងនិយាយថាយើងនឹងមិនមានឧបសគ្គណាមួយនៅក្នុងពិភពលោកនេះនោះទេ តែវាសន្មត់ថាយើងនឹងមាន។ តែទំនុកដំកើងនេះសន្យាថា ព្រះនឹងការពារយើងនៅក្នុងឧបសគ្គទាំងនេះ។ ព្រះយេស៊ូវសន្យាដូចគ្នាសំរាប់អ្នកដើរតាមទ្រង់ ហើយទ្រង់នឹងនាំយើងឲ្យទៅជាមួយទ្រង់ (យ៉ូហាន ១៤:១-៤, ២៧, ១៦:៣៣)។ យើងមិនគួរឲ្យគ្រោះថ្នាក់និងឧបសគ្គនៅក្នុងជីវិតបណ្តាលឲ្យយើងសង្ស័យលើព្រះ ឬងាកបែរចេញពីទ្រង់ ឬងាកបែរទៅឯពួកវិញ្ញាណឬរូបព្រះសំរាប់ជំនួយនោះទេ ប៉ុន្តែយើងគួរឲ្យគ្រោះថ្នាក់និងឧបសគ្គផ្សេងៗដឹកនាំយើងឲ្យងាកបែរមកឯព្រះដែលជាព្រះអាទិករ ព្រះដ៏ប្រោសលោះ និងព្រះអង្គការពាររបស់យើងវិញ។